# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបក្រុមធនាគារពិភពលោក (WB)



នៅរសៀលថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបពិភាក្សាការងារជាមួយក្រុមធនាគារពិភពលោក (WB) ដឹកនាំដោយលោកស្រី **Susanna Smets** ស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវិភាគទិន្នន័យលើវិស័យផ្គត់ផ្គង់ទឹកស្អាត នៅកម្ពុជា ។

ក្នុងកិច្ចប្រជុំនោះ តំណាងធនាគារពិភពលោក បានធ្វើបទបង្ហាញពីការអនុវត្តគម្រោងបានសម្រេចនាពេលកន្លងមក ដូចជា: -ការកសាងឯកសារស្តីពីតម្រូវការអាជីវកម្ម ដែលមានលំអិតអំពីភាពខុសគ្នាអំពីប្រភេទអ្នកប្រើប្រាស់ លំហូរការងារ និងការទទួលខុសត្រូវថ្មីនៃអ្នកប្រើប្រាស់ប្រភេទនីមួយៗនៅលើប្រព័ន្ធ និងមុខងាររបស់ប្រព័ន្ធ -ការកសាងឯកសារ ស្តីពីក្របខ័ណ្ឌត្រួតពិនិត្យ ដែលមានបរិយាយលម្អិតអំពីប្រភេទទិន្នន័យ និងសូចនាករ ដែលនឹងត្រូវវាយបញ្ចូលទៅក្នុងប្រព័ន្ធ ដើម្បីបំពេញការតម្រូវ ក្នុងការងារបញ្ជូនមកក្រសួងនូវទិន្នន័យ នៃរបាយការណ៍របស់ប្រតិបត្តិករទឹកស្អាត ទាំងវិស័យរដ្ឋ និងឯកជន-ក្រុមការងារបានធ្វើការទៅលើប្រភេទលេខកូដ **(Coding)** រួចបានដាក់ប្រព័ន្ធសម្រាប់ដំណើរការធ្វើតេស្តសាកល្បងចំនួន០៤លើក ។ ឆ្លងតាមលទ្ធផលនៃការធ្វើតេស្តចំនួន០៤លើក ក្រុមការងារបានរួមបញ្ចូលរាល់មតិយោបល់ ដែលបានលើកឡើង ទៅក្នុងការអនុវត្តការងារ **Coding** នៅក្នុងខេត្តចំនួនពីរ គឺ ខេត្តកណ្តាល និងកំពង់ចាម-មុននិងឈានដល់ការធ្វើតេស្តសាកល្បងទ្រង់ទ្រាយធំ ក្រុមការងារបានផ្តល់វគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធសាកល្បងនេះ រួមមានមន្ត្រីនាយកដ្ឋានទឹកស្អាត-មន្ត្រីមន្ទីរឧស្សាហកម្មខេត្តទាំងពីរ- ប្រតិបត្តិករទឹកស្អាត ទាំងរដ្ឋ និងឯកជននៃខេត្តទាំងពីរ និងតំណាងសមាគមទឹកស្អាតនៅកម្ពុជា ។

ទាក់ទងនិងគម្រោងការងារដែលកំពុងអនុវត្តបច្ចុប្បន្ន ស្តីពីការធ្វើតេស្តសាកល្បងទ្រង់ទ្រាយធំ គឺមន្ទីរឧស្សាហកម្មខេត្តទាំងពីរ បាននឹងបន្តជម្រុញ និងជួយជ្រោមជ្រែងប្រតិបត្តិករទឹកស្អាត ទាំងរដ្ឋ និងងឯកជន ក្នុងខេត្តទាំងពីរ ឱ្យប្រមូលព័ត៌មានចាំបាច់សម្រាប់ការវាយបញ្ចូលទៅក្នុងប្រព័ន្ធ។ រហូតមកដល់ពេលនេះ មន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្តកណ្តាលបានទទួលទិន្នន័យនៃរបាយការណ៍អំពីប្រតិបត្តិករទឹកស្អាតចំនួន១៧ រួចមកហើយ ហើយកំពុងតែជម្រុញបន្ត ។មន្ទីរឧស្សាហកម្ម

និងសិប្បកម្ម ខេត្តកំពង់ចាម ទទួលបានទិន្នន័យបានខ្លះ និងកំពុងជម្រុញបន្ថែម–ក្រុមការងារ និងមន្ត្រីគ្រប់គ្រងប្រព័ន្ធរបស់ក្រសួងបានបង្កើត User ID និង Password និងបានផ្តល់ជូនដល់អ្នកប្រើប្រាស់ទាំងអស់ដែលនឹងចូលរួម ក្នុងគម្រោងសាកល្បងនេះ ។



ចំពោះការងារដែលត្រូវបន្តអនុវត្តជំហ៊ានបន្ទាប់រួមមាន: –កែសម្រួលប្រព័ន្ធទៅតាមការចាំបាច់–កែសម្រួល និងផ្តល់ជូនក្រសួងនូវឯកសារទាំងឡាយ ដែលទាក់ទង និងការងារកសាងប្រព័ន្ធ ការងារធ្វើតេស្តសាកល្បង និងឯកសារបង្រៀនអ្នកប្រើប្រាស់–ដាក់ប្រព័ន្ធទៅលើសេវរេ និងភ្ជាប់ជាមួយ Domain របស់ក្រសួង នៅពាក់កណ្តាលខែកញ្ញា សម្រាប់ការប្រើប្រាស់ទូលំទូលាយទូទាំងប្រទេស ។ សម្រាប់ សេវាកម្ម Server នេះ គឺក្រុមការងារគម្រោងបានសម្រេចថា នឹងប្រើប្រាស់សេវាកម្ម Cloud Server ដែលផ្តល់ដោយក្រុមហ៊ុនក្រៅប្រទេសមួយដែលមានទំនុកចិត្ត–បន្ទាប់ពីចប់សព្វគ្រប់នូវការងារដាក់ប្រព័ន្ធទៅលើ Server និងភ្ជាប់ជាមួយ Domain របស់ក្រសួងរួចហើយ ក្រុមការងារនឹងបន្តអនុវត្ត ជាមួយនិងគម្រោងដាក់ដំណើរការប្រព័ន្ធសម្រាប់ការប្រើប្រាស់ទូលំទូលាយទូទាំងប្រទេសតែម្តង ។



បន្ទាប់ពីមន្ត្រីជំនាញខាងព័ត៌មានវិទ្យារបស់ធនាគារពិភពលោក ធ្វើបទបង្ហាញការធ្វើតេស្តសាកល្បងទៅលើប្រព័ន្ធត្រួតពិនិត្យតាមដាន និងវិភាគទិន្នន័យវិស័យទឹកស្អាត តាមប្រព័ន្ធ Internet រួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី បានមានមតិសរុប ដោយបានថ្លែងអំណរគុណចំពោះធនាគារពិភពលោក ដែលបានសហការជួយច្រើនដល់ក្រសួង ជាពិសេសលើការងារទឹកស្អាត ។ ជាក់ស្តែងការអនុវត្តគម្រោងប្រើប្រាស់ ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវិភាគទិន្នន័យវិស័យទឹកស្អាតនៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រសួង ដើម្បីពិនិត្យតាមដានពីដំណើរអាជីវកម្មទឹកស្អាត ទាំងវិស័យ រដ្ឋ និងឯកជន ពីព្រោះប្រព័ន្ធនេះ យើងអាចតាមដានដឹង ពីទីតាំងផលិតកម្ម សមត្ថភាពផ្គត់ផ្គង់ទឹក តម្លៃទឹក សេវាគ្របដណ្តប់ តំបន់សេវារបាយការណ៍ប្រចាំត្រីមាស ប្រចាំឆ្នាំជាដើម ។ តែជាសំណូមពរ ឯកឧត្តមស្នើឱ្យអ្នកជំនាញបញ្ចូលកម្មវិធី ដែលយើងអាចដឹងទៅដល់ភូមិនីមួយ ដែលមានបណ្តាញទឹកផ្គត់ផ្គង់ទៅដល់ ដែលនេះជាព័ត៌មានលំអិត ដែលយើងងាយស្រួលគ្រប់គ្រង តាមដាន និងជម្រុញការអភិវឌ្ឍន៍ ។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ស្នើឱ្យថ្នាក់ដឹកនាំទទួលបន្ទុក និងនាយកដ្ឋានជំនាញពិនិត្យតែងតាំង មន្ត្រីទទួលខុសត្រូវយ៉ាងតិចឱ្យបាន០៣នាក់ ក្នុងមុខងារកាន់កាប់ប្រព័ន្ធនីមួយៗ ដើម្បីងាយស្រួលប្តូរវេនគ្នា កុំឱ្យស្ទះការងារ ។

